## តើលោកអ្នកអាចធ្វើតេស្តមើលរោគរលាកថ្លើមជំពូក B ឬចាក់ថ្នាំការពារនៅកន្លែងណាដែរ?

- ចូរសាកសួរលោកគ្រូពេទ្យឬមន្ទីរមើលជំងឺរបស់លោកអ្នកអំពីការធ្វើតេស្តមើលរោគរលាកថ្លើមជំពូក *B* ។ សួរអំពីការចាក់ថ្នាំការពាររោគរលាកថ្លើមជំពូក *B* សម្រាប់អ្នក, កូនរបស់លោកអ្នក ហើយនិងសមាជិកនៃក្រុមគ្រួសាររបស់អ្នក។
- បើសិនជាលោកអ្នកពុំមានគ្រូពេទ្យទេ ចូរទូរស័ព្ទមកក្រសួងសុខាភិ បាលប្រចាំតំបន់លោកអ្នកសួរគេមើល តើគេធ្វើតេស្តមើលរោគរលាកថ្លើមជំពូក *B* ឬចាក់ថ្នាំការពារឬអត់។



ការពារខ្លួនលោកអ្នក, កូនរបស់លោកអ្នកហើយនិងសមាជិកនៃក្រុមគ្រួសាររបស់លោកអ្នកឱ្យផុតពីរោគរលាកថ្លើមជុំពូក *B* នេះ។ ការចាក់ថ្នាំការពាររោគរលាកថ្លើមជុំពូក *B* ត្រូវចាក់បីលើកអាចជួយការពារ លោកអ្នកឱ្យរួចផុតពីរោគដ៏កាចសាហាវនេះ។

បើសិនជាលោកអ្នកត្រូវការពត៌មានបន្ថែមស្តីអំពីរោគរលាកថ្លើមជំពូក *B* សូមទូរស័ព្ទទៅគ្រូពេទ្យ, ក្រសួងសុខាភិបាលប្រចាំតំបន់ របស់លោកអ្នកឬក៏ សុខមាលភាពមាតា សុខមាលភាពទារក *(Healthy Mothers, Healthy Babies)* តាមរយៈលេខ *1-800-322-2588*។

Washington State Department of
Health

*1-800-322-2588*
*Information and Referral Line*

*A service of*
*Healthy Mothers, Healthy Babies*
*Coalition of W ashington*

ដើម្បីស្នើសុំការបោះពុម្ពនេះ
ជាភាសាផ្សេងទៀត
សូមទូរស័ព្ទទៅ

*1-800-525-0127*

*DOH PUB 348-046 (7/98)*

# តើជនជាតិអាស៊ី និងជនជាតិរស់នៅកោះប៉ាស៊ីហ្វិក ចាំបាច់ត្រូវយល់អំពីរោគរលាកថ្លើមជំពូក B ដូចម្តេចដែរ?



Cambodian

ជនជាតិអាស៊ីនិងជនជាតិកោះប៉ាស៊ីហ្វិកអាចកើតរោគរលាកថ្លើមជំពូក *B* ច្រើន ជាងជនជាតិដ៏ទៃ ដោយសារ ពួកគេចាត់ទុកថា រោគរលាកថ្លើមជំពូក *B* នេះ ជារោគសាមញ្ញមួយ ដូចជានៅអាស៊ីអគ្នេយ៍, ប្រទេសចិន ហើយនិងកោះប៉ាស៊ីហ្វិក។



## តើរោគរលាកថ្លើមជំពូក B គឺជារោគអ្វីដែរ?

រោគនេះគឺជារោគដ៏ធ្ងន់ធ្ងរមួយបណ្ដាលមកពីមេរោគវិរុស (វិសាណូ) ធ្វើឱ្យខូចថ្លើម។ វាធ្វើឱ្យខូចថ្លើម, ក្លាយទៅជាមហារីកថ្លើមហើយដល់ថ្នាក់ស្លាប់ទៀតផង។

មនុស្សជាច្រើនកើតរោគរលាកថ្លើម តែអត់ធ្លាក់ខ្លួនឈឺទេ ហើយមិនដឹងថា ខ្លួនកើតរោគនោះផង។ ពួកគេអាចចម្លងរោគនោះទៅកូន ចៅរបស់គេ និងសមាជិកក្រុមគ្រួសារផ្សេងទៀតដោយមិនដឹងខ្លួន។

ទារកនិងកូនក្មេងទាំងឡាយកើតរោគរលាកថ្លើមជំពូក *B* អាចកើតរោគនេះអស់មួយជីវិតហើយកើតជាជំងឺថ្លើមពេលធំពេញវ័យ។

## តើរោគរលាកថ្លើមជំពូក B នេះឆ្លងតាមរបៀបណាដែរ?

រោគនេះឆ្លងពីមនុស្សម្នាក់ទៅម្នាក់ទៀតតាមរយៈឈាមកើតរោគនោះ ឬតាម រយៈទឹកក្នុងខ្លួន។ វាអាចឆ្លង :

- ◆ តាមការរួមរក្សផ្លូវភេទ
- ◆ ពីម្ដាយទៅទារកពេលឆ្លងទន្លេ
- ◆ តាមការប្រើម្ជុលចាក់ថ្នាំចូលគ្នា, ឡាមកោរពុកមាត់, ក្រវិលឬក៏ច្រាសដុះធ្មេញ
- ◆ ដោយទំពាអាហារបញ្ចុកកូនក្មេង

រោគរលាកថ្លើមជំពូក *B* ធម្មតាមិនឆ្លងតាម :

- ◆ ការកណ្ដាស់
- ◆ ក្អក
- ◆ ប្រើប្រាស់ចានជាមួយគ្នា
- ◆ កាន់ដៃគ្នា
- ◆ ទឹកដោះម្ដាយ

ទោះបីអ្នកកើតរោគរលាកថ្លើមជំពូក *B* ក៏ដោយ អ្នកអាចបំបៅដោះកូនដោយសុវត្ថិភាព ក៏ប៉ុន្តែ អ្នកត្រូវឈប់ភ្លាមបើសិនជាក្បាលដោះរបស់អ្នកប្រេះឈាមឬក៏ដំបៅតាមដោះ។

បើសិនជាលោកអ្នករស់នៅជាមួយអ្នកណាកើតរោគរលាកថ្លើមជំពូក *B* លោកអ្នកត្រូវប្រយ័ត្នឱ្យមែនទែន។ ទៅឱ្យគេធ្វើតេស្តមើលរោគនេះភ្លាម ហើយបើសិនជាលោកអ្នកមិនទាន់បានចាក់ថ្នាំការពារទេ ទៅចាក់ថ្នាំការពារទាំងបីលើកដើម្បីការពារខ្លួនលោកអ្នក។

## តើអ្នកណាខ្លះត្រូវការចាក់ថ្នាំការពាររោគរលាកថ្លើមជំពូក B ?

- ◆ បើសិនជាលោកអ្នកជាពូជពង្សនៃជនជាតិអាស៊ីឬក៏ជនជាតិនៃកោះប៉ាស៊ីហ្វិក នេះជាការសំខាន់ណាស់ បើលោកអ្នកនិង ក្រុមគ្រួសាររបស់អ្នកទៅធ្វើតេស្តមើលរោគរលាកថ្លើមជំពូក *B* នេះ។ បើសិនជាលោកអ្នកមិនទាន់បានចាក់ថ្នាំការពារ លោកអ្នកអាច ចាក់ចំនួនបីដងដើម្បីការពារឱ្យផុតពីរោគនេះ ។
- ◆ គ្រប់ទារកទាំងអស់កើតនៅក្នុងសហរដ្ឋអាមេរិកត្រូវចាក់ថ្នាំការពាររោគរលាកថ្លើមជំពូក *B* ឱ្យបានបីលើក។
- ◆ បើសិនជាកូនលោកអ្នកកើតនៅប្រទេសផ្សេង ឬបើសិនជាលោកអ្នកមិនច្បាស់ថា កូនលោកអ្នកបាន ចាក់ថ្នាំការពារនេះហើយឬនៅ ចូរសាកសួរគ្រូពេទ្យឬក៏មន្ទីរ មើលសុខភាពរបស់អ្នកឱ្យគេឆែកមើលឱ្យបានច្បាស់លាស់ថា កូនលោកអ្នកបានចាក់ថ្នាំការពារហើយឬនៅ។

